2

សាលាសាធារណៈភតឡ្សែន

# សេចក្តីណែនាំ អំពីការសិក្សា សម្រាប់គ្រួសារសិស្សសាលា

សេចក្តីសង្ខេបអំពីអ្វីខ្លះ ក្មេងៗ គួរដឹង គួរធ្វើ និងមធ្យោបាយនានា សម្រាប់គ្រួសារទាំងឡាយ បង្កើនការរៀនសូត្រនៅតាមគេហដ្ឋានរៀងៗខ្លួន ។




"យើងមានជំនឿថា គ្រប់គ្រួសារសិស្សសាលា គឺជាដៃគូ របស់យើង ។ ពួកគេទាំងនោះ គឺជាគ្រូដំបូង និងជាគ្រូដ៏មានអំណាចខ្លាំងក្លាលើសមនុស្សភាគច្រើន ចំពោះកូនទាំងឡាយ របស់ខ្លួន ។ ដោយការរួមសហការជាមួយគ្នា យើងនឹងអាចធានាថា សិស្សគ្រប់រូប នឹងមានជ័យជំនះ ក្នុងការរៀន របស់នាង"

-អគ្គនាយកសាលាសាធារណៈភតឡ្សែន លោក អ៊ីម៉ែននូអែល ខក

ថ្នាក់ទី២

## អំពីការណែនាំ ក្នុងការរៀនសូត្រទាំងនោះ:

ការណែនាំនេះ ជាតំណាងដំណឹងសំខាន់មួយ ដែលកូន របស់អ្នកគួរដឹង យើអាចធ្វើបាន មុននឹងដាច់ឆ្នាំសិក្សានេះ ជាភាសាអង់គ្លេសនិងលេខគណិត្រ ។ ទិសដៅ នៃការរៀនសូត្រនានា តែងជួយ គ្រួសារសិស្សនិងលោកគ្រូ/អ្នកគ្រូ បានជ្រាប ពេលណា ដែលសិស្សត្រូវការជំនួយបន្ថែម និងពេលណា ដែលគេត្រូវការមេរៀនសុក្រឹត ។

## តើគ្រួសារសិស្ស អាចធ្វើអ្វីបានខ្លះ ?

វាមានមធ្យោបាយជាច្រើន ដែលអ្នកអាចជួយការរៀនសូត្រ របស់កូនអ្នកបាន និងជួយពួកគេ ដើម្បីស្វែងរកអនាគត របស់គេ ។ តទៅនេះ គឺជាជំនួយខ្លះៗ ដែលនឹងអាចជួយសិស្ស ក្នុងការរៀនសូត្រ:

1. សូមប្រាប់កូនថា ការសិក្សាជាការសំខាន់ របស់កូន ។ ប្រាប់ពួកគេថា ការសិក្សាគឺជាអធិធាតុចម្បង គឺថា ជាប្រភព នៃជ័យជំនះ ។
2. ចាត់ទុកសាលារៀន ជាជំហានមុខ ។ នាំកូនចូលសាលារៀន តាមពេលម៉ោង រៀងរាល់ថ្ងៃ ។
3. រួមសហាការជាមួយសាលារៀន ដើម្បីបង្ហាញ នូវការគោរពគ្នាទៅវិញទៅមកជាមួយលោកគ្រូ/អ្នកគ្រូ និងបុគ្គលិក ។
4. សូមបង្ហំកូន ឱ្យធ្វើកិច្ចការរៀនសូត្រ ដោយខ្លួនឯង នាងអាចធ្វើខុសបាន ហើយត្រូវមានភាពទទួលខុសត្រូវ ចំពោះទង្វើទាំងឡាយ របស់ខ្លួន ។
5. និយាយជាមួយកូន អំពីអ្វី ដែលកំពុងតែកើតមាននៅសាលារៀន ។
6. ពិភាក្សាជាមួយគ្រូ របស់កូនអ្នក ដើម្បីធានាថា ពួកគេមានការរីកចម្រើន ក្នុងឆ្នាំសិក្សានិមួយៗ ។
7. ចូលប្រជុំជាមួយគ្រូ និងពិធីជួបជុំដទៃទៀត នៅសាលារៀន តាមដែលអាចធ្វើទៅបាន ។
8. អ្នកមានសិទ្ធិទទួលដំណឹង អំពីការសិក្សា របស់កូន ។ សូមកុំខ្លាចក្រែង ក្នុងការទាក់ទងគ្រូ របស់កូន បើមានសំណួរ ។

## ការពិភាក្សាជាមួយនិងគ្រូ នៃកូន របស់អ្នក

វាជាការមួយយ៉ាងសំខាន់ ក្នុងការសន្ទនាជាមួយគ្រូកូនអ្នកនិងសាលារៀនជាធម្មតា អំពីការរីកចម្រើន ទៅនិងទិសដៅរៀនសូត្រ របស់កូន ។ ខាងក្រោមនេះ ជាសំណួរឬប្រធានបទនានា ដែលអ្នកគួរពិភាក្សា ជាមួយគ្រូបង្រៀន:

- សូមពិនិត្យការណែនាំ អំពីការរៀនសូត្រនេះ ហើយសួរថា ចំណុចខ្លាំង របស់កូនគឺអ្វីខ្លះ និងត្រូវការកែលម្អលើចំណុចណាខ្លះ ។
- បន្ថែមពីលើគោលដៅ នៃការសិក្សាទាំងនោះ ក្នុងការណែនាំនេះ តើវានៅមានគោលដៅដទៃណាមួយទៀត សម្រាប់កូន របស់អ្នកឬទេ?
- សុំគ្រូមើលសំណៅសិក្សា របស់កូន តើគេរៀនបានសម្រេចតាមទិសដៅឬទេ ។
- សួរគេថា ការធ្វើតិសចំណេះវិជ្ជា របស់សិស្ស ដោយវិធីណា ក្នុងរយៈមួយឆ្នាំ នៃការសិក្សានោះ ។
- សួរគ្រូថា តើកូនអ្នករៀនបានសម្រេច តាមគោលបំណង នៃកម្រឹតថ្នាក់ របស់នាងឬទេ ។ បើពុំដូច្នោះទេ តើសាលាមានជំនួយអ្វី សម្រាប់នាងឬទេ? តើអ្នកជាមាតាបិតា អាចជួយអ្វីបានខ្លះ នៅផ្ទះ?

- សួរគ្រូថា តើកូនអ្នករៀនបានសម្រេច តាមការរំពឹងទុកជាមុនឬក៏ប្រសើរជាងការរំពឹងទុក ។ បើពុំដូច្នោះទេ តើសាលាមានជំនួយអ្វី សម្រាប់នាងឬទេ? តើអ្នកជាមាតាបិតា អាចជួយអ្វីបានខ្លះ នៅផ្ទះ?

## និយាយជាមួយកូនអ្នក

"តើមានការសប្បាយរីករាយសុខទុក្ខយ៉ាងណា នៅសាលាថ្ងៃនេះ?"
"សុខសប្បាយជាធម្មតាទេ"
"តើកូនបានធ្វើអ្វីខ្លះនៅសាលាថ្ងៃនេះ?"
"គ្មានធ្វើអ្វីទេ"

តើអ្នកធ្លាប់បានឮសំណួរ/ចម្លើយទាំងនេះឬទេ? មិនអីទេ តោងតែសួរបន្តទៅទៀត ! សិស្សទាំងឡាយ ដែលឪពុកម្តាយគេ តែងតែសាកសួរ អំពីការរៀនសូត្រ តែងតែរៀនសូត្របានល្អប្រសើរនៅ សាលារៀន ។ តទៅនេះ ជាមធ្យោបាយខ្លះៗ ដែលអ្នកអាចទាក់ទាញកូន និងជួយឱ្យនាងរៀនបានសម្រេចៈ

- សូមឆ្លៀតឱកាសនិយាយជាមួយកូនអ្នក អំពីសាលារៀនឱ្យបានរៀងរាល់ថ្ងៃ ។
- សូមឱ្យកូននិយាយប្រាប់អ្នក អំពីអ្វីមួយ ដែលនាងបានរៀន នៅថ្ងៃនេះ ។ អ្វី ដែលកូនអ្នកតែងគិត តែងតែគួរឱ្យចាប់អារម្មណ៍ជាទីបំផុត ។ តើមានអ្វី ដែលគួរឱ្យពិបាកឬទេ ?
- សូមពិនិត្យឡើញវិញ នូវក្រដាសនិងគម្រោងការសិក្សាទាំងឡាយ ដែលកូនអ្នកយកពីសាលារៀន ។ សួរកូនឱ្យប្រាប់អ្នកថា តើក្រដាសឬគម្រោងការសិក្សានោះ ចង់បង្រៀនកូន អំពីអ្វីខ្លះ ។
- សូមសរសើរកូនអ្នក ចំពោះការប្រឹងរៀនសូត្រនិងការព្យាយាម កុំគិតតែពីចម្លើយត្រឹមត្រូវពេក ។
- សួរកូនថា តើនាងកំពុងតែគិត អំពីអ្វីៈ តើនាងដឹង ដោយវិធីណា? តើនាងគិតថាដូចម្តេច? តើនាងមានកត់សម្គាល់លើអ្វីទេ? តើហេតុអ្វី បានជានាងគិតដូច្នោះ? តើនាងមានមធ្យោបាយ ដទៃទៀត ដើម្បីរកចម្លើយឬទេ?

## ជំនួយការរៀនសូត្រ ក្រៅពីសាលារៀន

ការរៀនសូត្រ មិនត្រូវបញ្ចប់ទេ ពេលណា ដែលសិស្សចេញពីសាលារៀននោះ ។ សិស្សទាំងឡាយ ចំណាយពេលក្រៅសាលារៀន ច្រើនជាងនៅសាលារៀន ។ ខាងក្រោមនេះ ជាមធ្យោបាយខ្លះៗ អ្នក អាច ជួយបង្រៀនកូន ក្រៅសាលារៀនៈ

- សូមអានឱ្យកូនស្តាប់ អានជាមួយនិងកូន ហើយណាត់ពេលមួយ ដើម្បីគ្រួសារទាំងមូល អានជុំគ្នា - ជាភាសាណាមួយ ដែលអ្នកអានបានល្អ ។
- រកទីកន្លែងស្ងាត់ស្ងៀម និងមានបរិយាកាសល្អ សម្រាប់កូនអ្នកធ្វើកិច្ចការសាលាឬកិច្ចការរៀនសូត្រ ដទៃទៀត ។
- ព្យាយាមបង្កើតពេលវេលាទៀងទាត់ សម្រាប់ធ្វើកិច្ចការសាលាឬក៏កិច្ចការរៀនសូត្រដទៃទៀត ។
- ប្រើការណែនាំនេះ សង្កត់ធ្ងន់លើគោលដៅរៀនសូត្រមួយចំនួន។ សាកល្បងអនុវត្ត នូវទ្រឹស្តីខ្លះ ដែលបានជម្រាបមកខាងលើនេះ នៅផ្ទះ ។

# តើសិស្ស របស់អ្នកត្រូវការដឹង អំពីអ្វី ហើយនឹងអាចធ្វើអ្វី ក្នុងភាសាអក្សរសាស្ត្រ:

## ភាសា

- ❑ និយាយសារឡើងវិញ នូវដំណឹងជាគន្លឹះឬគំនិតអត្ថបទ ដកស្រង់ចេញពីការពិភាក្សាឬការអានរឿងបញ្ចេញសម្លេង ។
- ❑ បញ្ជាក់អត្ថន័យត្រឹមត្រូវពាក្យនិមួយៗ ដែលអាចមានន័យច្រើនយ៉ាង ទៅតាមការប្រើ របស់វាក្នុងអត្ថបទនិមួយៗ។ ″ ឧទាហរណ៍ - មើលប្រយោគចុងក្រោយឬឃ្លា ដើម្បីឱ្យច្បាស់ថា ពាក្យ"saw" មានន័យថា គ្រឿងឧបករណ៍ឬក៏មានន័យថា អតីតកាល របស់ពាក្យ see (ប្រែថា មើលឃើញ) ។
- ❑ សន្និដ្ឋានលើអត្ថន័យពាក្យថ្មី កាលណាឃើញមានបុព្វបទសាមញ្ញនាំមុខពាក្យមិនធ្លាក់ឃើញ ។ ឧទាហរណ៍ ដូចជាពាក្យ happy/unhappy, tell/retell.

## ការអានអក្សរ និងការអានអក្សរសិល្ប៍

- ❑ ធ្វើការសន្និដ្ឋានជាមុន អំពីគំនិតអត្ថបទ របស់សៀវភៅរឿងពិត ដោយការប្រើចំណេះអតីតកាលនិងគម្រោងសៀវភៅ មានដូចជា ចំណងជើង មាតិការឿង
ជំណងជើងក្រោមរូបភាពនិងពាក្យគន្លឹះនានា ។
- ❑ ឱ្យសិស្សនិយាយសារឡើងវិញ នូវរឿង ដែលនាងបានអានមកហើយ ។
- ❑ ធ្វើការឧប្បមា/ឧប្បម័យ ចំពោះតួអត្ថន័យផ្សេងគ្នា ក្នុងរឿងតែមួយ ។

## ការសរសេរ

- ❑ សរសេរបញ្ចេញយោបល់ផ្ទាល់ខ្លួន អំពីរឿងណាមួយ ដែលនាងបានអាន, ប្រើសេចក្តីអមសំខាន់ៗ ដកស្រង់ចេញពី សៀវភៅ ដើម្បីគាំទ្រយោបល់នោះ ។
- ❑ សរសេរសេចក្តីណែនាំធ្វើអ្វីមួយ ឱ្យបានច្បាស់លាស់គឺការរៀបរាប់តាមលំដាប់ឬវិធីការ ដូចជា របៀបតម្លើងតុសម្រាប់ម្ហូបអាហារទទួលទានឬក៏ការលេងល្បែងប្រជាប្រិយភាពណាមួយ ។
- ❑ សរសេររឿង ដោយមានសេចក្តីផ្តើម តួសេចក្តីនិងបញ្ចប់សេចក្តីច្បាស់លាស់ ។



# មធ្យោបាយនានា
# ដើម្បីលើកទឹកចិត្តសិស្សឱ្យប្រឹងរៀនភាសានៅតាមផ្ទះ

- ❑ រកមើលឧទាហរណ៍នានា របស់វចនស័ព្ទទាំងឡាយ ដែលមានន័យពីរ-បីយ៉ាងផ្សេងៗគ្នា (ដូចជាពាក្យ run, saw និង blue) ។ និយាយអំពីរបៀប ដែលតួសេចក្តីអាចជួយយើងឱ្យយល់ថាពាក្យនោះមានន័យយ៉ាងណា ពេលប្រើក្នុងនោះ ។ លើកទឹកចិត្តកូនឱ្យរកមើលឧទាហរណ៍ពាក្យទាំងឡាយណា ដែលមានន័យច្រើនយ៉ាង ពេលណានាងអានសៀវភៅ ។
- ❑ អាននិងនិយាយអំពីសៀវភៅជាមួយគ្នា ។ បន្ទាប់ពីបានអានសៀវភៅរឿងពិតណាមួយមក និយាយអំពីអ្វី ដែលនាង បានរៀនសូត្រ ហើយអ្នកក៏គួរបញ្ចេញអ្វី ដែលអ្នកបានរៀនសូត្រផងដែរ ។ ក្រោយការអានរឿងប្រលោមលោក សូមឱ្យ កូនអ្នកនិយាយអំពីហេតុអ្វី ដែលបានកើតឡើងនៅដើមរឿង កណ្តាលរឿង និងនៅខាងចុងសាច់រឿង ។
- ❑ ជួយកូនអ្នកសរសេររបៀបធ្វើម្ហូប ដែលមានដាក់គ្រឿងតាមលំដាប់លំដោយ ដើម្បីធ្វើម្ហូបជាទីពេញចិត្តណាមួយ ។   ឧទាហរណ៍ - វិធីធ្វើ peanut butter នឹង jelly sandwich ឬក៏ fruit Salad ។
- ❑ សួរបណ្ណារក្សក្នុងភូមិ របស់អ្នក រកយោបល់ថា មានសៀវភៅឬសៀវភៅរឿងណាមានប្រភេទផ្សេងៗគ្នា នៃរឿងព្រេងទាំងឡាយ ។ អានសៀវភៅបញ្ចេញសម្លេង ជាមួយនិងកូនអ្នក ហើយពិភាក្សា អំពីការដូចគ្នានិងខុសគ្នាយ៉ាងណាខ្លះ ។

Notes:

______________________________

______________________________

______________________________

______________________________

______________________________

______________________________

______________________________

______________________________

______________________________

______________________________

______________________________

ម្យ៉ាងទៀត សូមបន្តការទាក់ទងជាមួយគ្រូកូនអ្នកនិងសួររកអំពីសម្ភារៈអ្វីខ្លះ អាចរៀននៅផ្ទះ ដែលមានភាពប្រហាក់ប្រហែលគ្នានិងកម្មវិធីបង្រៀនអាននិងសរសេរនៅសាលារៀនកូន របស់អ្នក ។

# តើអ្វី ដែលសិស្សត្រូវយល់ដឹង និងអាចធ្វើបានជាមួយលេខគណិត្រៈ

- យល់និងចេះដោះស្រាយលេខបូកនិងលេខសង ដោយការប្រើវិធីសាស្ត្រនិងឧបករណ៍ ដូចជាការតម្រៀបលេខជាជួរ ។
- យល់និងប្រើទំនាក់ទំនងរវាងការបូកនិងដកលេខ ។ ឧទាហរណ៍- ផ្លែប៉ោមទាំងអស់មាន១០ ។ ផ្លែប៉ោម៦ ដាក់លើតុ ហើយសល់ពីនោះ នៅក្នុងថង់ ។ តើនៅក្នុងថង់នោះ មានផ្លែប៉ោមប៉ុន្មាន? ខ្ញុំអាចបូកលេខ ដើម្បីធ្វើចំណោទនេះ: ១៦ + ? = ៣០ ។ វាមាន១៤ផ្លែប៉ោម នៅក្នុងថង់នោះ ។
- ធ្វើលេខជាគម្រូងាយស្រួល មានដូចជា ៦+៣=១៤, ១៤-៨=៦ ។
- សម្គាល់និងតំណាងប្រភាគទូទៅ ដូចជា ១/២, ១/៣, និង ១/៤, ជាប្រភាគស្មើគ្នា នៃរបស់មួយ (១/២ នៃរាងបួនជ្រុងទ្រវែង) និងភាគស្មើគ្នា នៃក្រុមមួយ (១/២ នៃនំក្រៀម១២ គឺ ៦នំ) ។
- ពន្យល់រៀបរាប់ បន្ថែម និងបង្កើតភាពដដែលៗ ដោយការប្រើរូបសណ្ឋាន ពណ៌និងលេខ ។
- រៀបរាប់ន័យ របស់រូបសណ្ឋានមានខ្នាតពីរនិងខ្នាតបី ។
- ធ្វើការប្រៀបធៀប និងដាក់តាមលំដាប់លំដោយ នៃប្រវែងរបស់ផ្សេងគ្នា ។
- គូសតំណាង និងពន្យល់ប្រភព រួមទាំងចំណុចបន្ទាត់ណាមួយ ។ ឧទាហរណ៍- តើសិស្សទាំងអស់ស្លៀកខោអាវ មានហោប៉ៅប៉ុន្មាន នៅថ្ងៃនេះ?



# ការរៀនលេខគណិត្រ នៅតាមផ្ទះ

- ❑ រកមើលរបស់ណា ដែលមានមកជាក្រុមៗ ដូចជា មនុស្សម្នាក់មានជើងពីរ, ឡានមួយមានកង់បួន ។ សួរកូនឱ្យគិតលេខ តើមនុស្ស៨នាក់មានជើងប៉ុន្មាន ឬក៏ ឡាន៥មានកង់ប៉ុន្មាន?
- ❑ ធ្វើតារាងកាលវិភាគ ជាមួយកូនអ្នក សម្រាប់ថ្ងៃសៅរ៍ឬថ្ងៃអាទិត្យ ដោយប្រើពេលមួយម៉ោងឬកន្លះម៉ោង ។ ឧទាហរណ៍- អាហារថ្ងៃត្រង់ម៉ោង១២:៣០, ម៉ោង១:០០ចេញដំណើរទៅលេងសួនឱទ្យាន ។ និយាយជា មួយកូនអ្នក អំពីម៉ោងនិមួយៗនៅលើនាឡិកាដូចអ្វីខ្លះ ។
- ប្រើសភាពការរៀងរាល់ថ្ងៃ ដើម្បីរកមើលនិងប្រើភាគបែងងាយៗ ដូចជា ១/២, ១/៣និង ១/៤ នៃរបស់អ្វីមួយ ។ ឧទារណ៍- កាត់នំប៉័ងញាត់សាច់ជាពីរស្មើគ្នាឬបត់កាសែតជាបួនផ្នត់ស្មើភាគគ្នា ។
- សួរកូនឱ្យគិត អំពី១/២ នៃក្រុមរបស់របរអ្វីមួយ ។ ឧទារណ៍- បើកូនអ្នកមានកាតបេស្ហបល២៤សន្លឹក ដើម្បី ចែកស្មើៗគ្នាជាមួយមិត្ររបស់ខ្លួន តើម្នាក់ៗត្រូវបានប៉ុន្មានសន្លឹក? ។
- ប្រើបន្ទាត់ជាមួយកូនអ្នកឬក៏ម៉ែត្រ ដើម្បីវាស់ប្រវែង វត្ថុនានា ក្នុងផ្ទះរបស់អ្នក ។ សុំឱ្យកូនអ្នកប្រៀបធៀប នូវប្រវែង នៃវត្ថុទាំងនោះ ។

Notes:

ម្យ៉ាងទៀត សូមបន្តការទាក់ទងជាមួយគ្រូកូនអ្នកនិងសួររកអំពីសម្ភារៈអ្វីខ្លះ អាចរៀននៅផ្ទះ ដែលមានភាពប្រហាក់ប្រហែលគ្នានិងកម្មវិធីបង្រៀនលេខគំណិត្រនៅសាលារៀនកូន របស់អ្នក ។

សាលាសាធារណៈភតឡែន
ការិយាល័យវិជ្ជាបង្រៀន
លេខ ៣៥៣ មហាវិថីខាំបើឡែន
ភតឡែន, រដ្ឋម៉េន ០៤១០១
២០៧ ៨៧៤ ៨១០០
portlandschools.org

លិខិតចេញផ្សាយនេះ បោះពុម្ព ដោយសាលាសាធារណៈភតឡែន
។ អត្ថបទប្រើប្រាស់ និងការកែសម្រួល ដោយមានការអនុញ្ញាត
អំពីសាលាសាធារណៈបោះស្តុន ។៉អត្ថបទ បន្ថែមពីនោះទៀត ជារបស់ បណ្ឌិត
អែនថូនី ម៉ោ ។

Created spring 2014

**Khmer**